# 06 저는 투안입니다

ខ្ញុំគឺធូអាន់

**학습 안내**
ការណែនាំអំពីមេរៀន

| | |
|---|---|
| □ វត្ថុបំណងមេរៀន | ការណែនាំខ្លួន |
| □ វេយ្យាករណ៍ | 입니다, 입니까 |
| □ ពាក្យថ្មី | ប្រទេស, មុខរបរ |
| □ ព័ត៌មាន · វប្បធម៌ | សុជីវធម៌ក្នុងការសម្តែងការគួរសម |

## 대화 1 ការសន្ទនា ១

Track 22



ខាងក្រោមនេះគឺជាការសន្ទនារវាងមីនស៊ូនិងធូអាន់។ អ្នកទាំង២កំពុងតែធ្វើការណែនាំខ្លួនទៅវិញទៅមក។ សូមស្តាប់ការសន្ទនាឲ្យបាន២ដងជាមុនសិន រួចហើយចូរថាតាម។

**민수** 안녕하세요.
ជម្រាបសួរ។
저는 이민수입니다.
ខ្ញុំគឺមីនស៊ូ។

**투안** 안녕하세요.
ជម្រាបសួរ។
저는 투안입니다.
ខ្ញុំគឺធូអាន់។
저는 베트남 사람입니다.
ខ្ញុំគឺជាជនជាតិវៀតណាម។

> **저** ខ្ញុំ
> ប្រើប្រាស់ពាក្យនេះដើម្បីបង្ហាញការគោរពចំពោះដៃគូសន្ទនាក្នុងការហៅខ្លួនឯង។
> - 저는 이영진입니다.
>   ខ្ញុំគឺអ៊ីយ៉ង់ជីន។
> - 저는 캄보디아 사람입니다.
>   ខ្ញុំគឺជាជនជាតិខ្មែរ។

> **안녕하세요** ជម្រាបសួរ
> ប្រើប្រាស់ពាក្យនេះ ដើម្បីសម្តែងការគួរសមទៅកាន់នរណាម្នាក់នៅពេលជួបគ្នា។
> - 안녕하세요. 저는 이민수입니다.
>   ជម្រាបសួរ។ ខ្ញុំគឺអ៊ីមីនស៊ូ។
> - 안녕하세요. 만나서 반갑습니다.
>   ជម្រាបសួរ។ រីករាយណាស់ដែលបានជួបអ្នក។



តើអ្នកបានស្តាប់និងថាតាមការសន្ទនារួចហើយមែនដែរឬទេ?
អញ្ចឹងសូមឆ្លើយសំណួរខាងក្រោម។

1. 투안 씨는 누구와 인사를 했어요? តើធូអាន់បានសម្តែងការគួរសមជាមួយនរណា?
2. 투안 씨는 어느 나라 사람이에요? ធូអាន់គឺជាជនជាតិអ្វី?

**정답** 1. 민수 씨와 인사를 했어요. 2. 베트남 사람입니다.

## 어휘 1 ពាក្យថ្មី ១ | 나라 ប្រទេស



ខាងក្រោមនេះគឺជាទង់ជាតិនៃប្រទេសមួយចំនួនដែលមានប្រជាជនមកធ្វើការនៅក្នុងប្រទេសកូរ៉េ។ តើមានប្រទេសណាខ្លះ យើងនឹងមកស្វែងយល់ជាមួយគ្នា។



캄보디아
កម្ពុជា



스리랑카
ស្រីលង្កា



네팔
នេប៉ាល់



동티모르
ទីម័រខាងកើត



필리핀
ហ្វីលីពីន



라오스
ឡាវ



몽골
ម៉ុងហ្គោល



미얀마
មីយ៉ាន់ម៉ា



방글라데시
បង់ក្លាដែស



베트남
វៀតណាម



태국
ថៃ



우즈베키스탄
អ៊ូសបេគីស្ថាន



인도네시아
ឥណ្ឌូនេស៊ី



중국
ចិន



키르기스스탄
កៀហ្ស៊ីស៊ីស្ថាន



파키스탄
ប៉ាគីស្ថាន

### Tip 입니다 គឺជា

នៅក្នុងភាសាអង់គ្លេសពាក្យថា 'to be' គឺផ្លាស់ប្តូរទៅតាមប្រធានដែលមានដូចជា៖ 'am', 'are', 'is' ជាដើម។ ប៉ុន្តែនៅក្នុងភាសាកូរ៉េវិញ មិនចំពោះប្រធានជាមនុស្សទីប៉ុន្មាននោះទេ យើងប្រើប្រាស់ '-입니다' ទាំងអស់។ មិនត្រឹមតែប៉ុណ្ណោះ នៅក្នុងភាសាអង់គ្លេសនៅពេលដែលប្រែទៅជាប្រយោគសំណួរ លំដាប់នៃពាក្យនៅក្នុងប្រយោគត្រូវបានផ្លាស់ប្តូរ ប៉ុន្តែនៅក្នុងភាសាកូរ៉េវិញ យើងផ្លាស់ប្តូរត្រឹមតែកិរិយាស័ព្ទតែប៉ុណ្ណោះ។ អញ្ចឹងហើយ នៅក្នុងប្រយោគស្របយើងប្រើប្រាស់ '입니다' ចំណែកឯនៅក្នុងប្រយោគសំណួរវិញយើងប្រើប្រាស់ '입니까'។

- 이것은 펜입니다. នេះគឺជាប៊ិក។
- 이것은 펜입니까? តើនេះគឺជាប៊ិកឬ?

## 문법 1 វេយ្យាករណ៍ ១ | 입니다

G06-1

'입니다' ត្រូវបានប្រើប្រាស់ក្នុងការចង្អុលបង្ហាញអំពីអ្វីមួយតាមរយៈប្រធានដើម្បីបង្កើតបានទៅជាប្រយោគមួយ។ យើងប្រើប្រាស់វាជាមួយនាមដើម្បីបង្ហាញការគោរពដល់ដៃគូសន្ទនា ឬក៏នៅក្នុងស្ថានភាពផ្លូវការជាដើម។

- 저는 한국 사람**입니다**. ខ្ញុំគឺជាជនជាតិកូរ៉េ។
- 저는 민수**입니다**. ខ្ញុំគឺមីនស៊ូ។

### 비교해 보세요 សូមសាកល្បងធ្វើការប្រៀបធៀប

✔ រវាង '입니다' និង '이/가 아닙니다'

'입니다' ត្រូវភ្ជាប់ជាមួយនាម ដើម្បីបញ្ជាក់លក្ខណៈរបស់ប្រធានឲ្យទៅជាប្រយោគមួយដែលមានន័យពេញលេញអាចស្ដាប់បាន។ បើចង់ប្រើប្រាស់ទៅជាប្រយោគបដិសេធវិញនោះយើងត្រូវប្ដូរ '입니다' ទៅជា '아닙니다' វិញ។ ម្យ៉ាងទៀត '아닙니다' តែងតែប្រើប្រាស់ជាទម្រង់ '이/가 아닙니다' ជានិច្ច។ '아닙니다' ជាអ្នកបញ្ជាក់លក្ខណៈនៃប្រធាន ហេតុនេះហើយត្រូវសរសេរដកឃ្លាពីពាក្យដែលនៅពីខាងមុខវា។

- 저는 한국 사람**입니다**.(O)
- 저는 한국 사람아닙니다.(X)
- 저는 한국 사람**이 아닙니다**.(O)



តើអ្នកបានយល់អំពីការប្រើប្រាស់ '입니다' ហើយមែនដែរឬទេ? សូមសាកល្បងធ្វើតាម<ឧទាហរណ៍> ដោយបញ្ចប់ការសន្ទនាខាងក្រោមនេះឲ្យបានត្រឹមត្រូវ។

1. 〈보기〉처럼 문장을 완성하세요. សូមធ្វើតាម<ឧទាហរណ៍>ដោយបញ្ចប់ប្រយោគឲ្យបានត្រឹមត្រូវ។

보기



투안

저는 투안입니다. ខ្ញុំគឺធួអាន់។

1) 

리한

______________________.

2) 

수피카

______________________.

2. 〈보기〉처럼 문장을 완성하세요. សូមធ្វើតាម<ឧទាហរណ៍>ដោយបញ្ចប់ប្រយោគឲ្យបានត្រឹមត្រូវ។

보기



베트남

저는 베트남 사람입니다. ខ្ញុំគឺជាជនជាតិវៀតណាម។

1) 

파키스탄

______________________.

2) 

태국

______________________.

정답 1. 1) 저는 리한입니다 2) 저는 수피카입니다 2. 1) 저는 파키스탄 사람입니다 2) 저는 태국 사람입니다

## 대화 2 ការសន្ទនា ២

Track 23

ធូអាន់និងជូនគូកំពុងតែធ្វើការណែនាំខ្លួនទៅវិញទៅមក។ ពួកគេកំពុងតែនិយាយអំពីសញ្ជាតិនិងមុខរបរថែមទៀតផង។ តើអ្នកទាំង២មកពីប្រទេសណាខ្លះ? សូមស្ដាប់ការសន្ទនាឲ្យបាន២ដងជាមុនសិន។

**투안** 저는 투안입니다.
ខ្ញុំគឺធូអាន់។

**준구** 어느 나라 사람입니까?
តើអ្នកគឺជាជនជាតិអ្វី?

**투안** 베트남 사람입니다.
ខ្ញុំគឺជាជនជាតិវៀតណាម។

**준구** 학생입니까?
តើអ្នកគឺជាសិស្សរឺ?

**투안** 아니요, 회사원입니다.
មិនមែនទេ, ខ្ញុំគឺជាបុគ្គលិកក្រុមហ៊ុន។

**어느** មួយណា

មួយណា+នាម។
ជាពាក្យដែលប្រើដើម្បីសាកសួរជាសំណួរថាក្នុងចំណោមទាំងអស់ តើមួយណាដែលត្រឹមត្រូវ។

- 가: 어느 나라 사람입니까?
  តើអ្នកគឺជាជនជាតិអ្វី?
  나: 한국 사람입니다.
  ខ្ញុំគឺជាជនជាតិកូរ៉េ។

**아니요** មិនមែនទេ

ប្រើប្រាស់នៅពេលដែលអ្វីមួយមិនមែនជាការពិត។ ប្រសិនបើអ្វីមួយដែលត្រឹមត្រូវ ត្រូវប្រើ '네' ជំនួសវិញ។

- 가: 러시아 사람입니까?
  តើអ្នកជាជនជាតិរុស្សីមែនដែររឺទេ?
  나: 아니요, 캄보디아 사람입니다.
  មិនមែនទេ, ខ្ញុំគឺជាជនជាតិខ្មែរ។

ម្ដងនេះសូមអ្នកធ្វើជាតួអង្គធូអាន់និងជូនគូហើយសាកល្បងថាតាមការសន្ទនា។ តើអ្នកបានស្ដាប់និងថាតាមរួចហើយមែនដែរឬទេ? អញ្ចឹងសូមឆ្លើយសំណួរខាងក្រោម។

1. 투안 씨는 어느 나라 사람이에요? តើធូអាន់គឺជាជនជាតិអ្វី?

2. 투안 씨의 직업은 뭐예요? តើធូអាន់មានមុខរបរអ្វី?

정답 1. 베트남 사람입니다. 2. 회사원입니다.

## 어휘 2 ពាក្យថ្មី ២ | 직업 មុខរបរ



យើងនឹងស្វែងយល់អំពីពាក្យថ្មីមួយចំនួនដែលទាក់ទងទៅនឹងមុខរបរចិញ្ចឹមជីវិត។



학생
សិស្ស



선생님
គ្រូបង្រៀន



회사원
បុគ្គលិកក្រុមហ៊ុន



주부
មេផ្ទះ



경찰관
មន្ត្រីប៉ូលីស



소방관
អ្នកពន្លត់អគ្គិភ័យ



공무원
មន្ត្រីរាជការ



점원
អ្នកលក់ក្នុងហាង



의사
គ្រូពេទ្យ



간호사
គិលានុបដ្ឋាយិកា



요리사
ចុងភៅ



운전기사
អ្នកបើកបរ



기술자
អ្នកបច្ចេកទេស



목수
ជាងឈើ



농부
កសិករ



어부
អ្នកនេសាទ



សូមរំលឹកពីពាក្យដែលបានរៀននៅខាងលើម្តងទៀត បន្ទាប់មកចូរសាកល្បងដោះស្រាយសំណួរខាងក្រោម។

1. 그림을 보고 〈보기〉처럼 알맞은 말을 연결하세요.
សូមមើលរូបភាព បន្ទាប់មកចូរភ្ជាប់ទៅនឹងពាក្យដែលបានត្រឹមត្រូវដូច<ឧទាហរណ៍>។

보기 

① 

② 

③ 

④ 

㉠ 주부 ㉡ 의사 ㉢ 학생 ㉣ 경찰관 ㉤ 회사원

정답 ① ㉢ ② ㉠ ③ ㉤ ④ ㉣

## 문법 2 វេយ្យាករណ៍ ២ | 입니까

G06-2

'입니까?' គឺជាប្រយោគក្នុងទម្រង់សំណួរដែលចេញពី '입니다' ប្រើប្រាស់នៅពេលដែលសាកសួរអំពីអ្វីមួយ។ វាដូចជា '입니다' អញ្ចឹងសម្រាប់ប្រើប្រាស់ក្នុងស្ថានភាពផ្លូវការដើម្បីសម្តែងការគោរពដល់ដៃគូសន្ទនា។

- 가: 회사원**입니까**? តើអ្នកគឺជាបុគ្គលិកក្រុមហ៊ុនឬ?
  나: 네, 회사원입니다. បាទ/ចាំ, ខ្ញុំគឺជាបុគ្គលិកក្រុមហ៊ុន។
- 가: 어느 나라 사람**입니까**? តើអ្នកគឺជាជនជាតិអ្វី?
  나: 저는 캄보디아 사람입니다. ខ្ញុំគឺជាជនជាតិខ្មែរ។



តើអ្នកបានយល់អំពីការប្រើប្រាស់ '입니까?' ហើយមែនដែរឬទេ? អញ្ចឹងសូមសាកល្បងធ្វើតាម <ឧទាហរណ៍>ដោយបញ្ចប់ប្រយោគខាងក្រោមនេះ។

2. 〈보기〉처럼 문장을 완성하세요. សូមធ្វើតាម<ឧទាហរណ៍>ដោយបញ្ចប់ប្រយោគឲ្យបានត្រឹមត្រូវ។

보기 학생 → 학생입니까? តើអ្នកគឺជាសិស្សឬ?

1) 회사원 → ______________________?

2) 소방관 → ______________________?

3) 간호사 → ______________________?

4) 기술자 → ______________________?

정답 1) 회사원입니까 2) 소방관입니까 3) 간호사입니까 4) 기술자입니까



រៀនថែមបន្តិចទៀតតើល្អដែរឬទេ? សូមមើលរូបភាព រួចហើយប្រើប្រាស់'입니까' មកបញ្ចប់ល្បះខាងក្រោម។

1) 

가: 중국 사람입니까?

나: 아니요, ______________________.

2) 

가: 간호사 ______________________?

나: 아니요, ______________________.

3) 

가: 요리사 ______________________?

나: 아니요, ______________________.

정답 1) 태국 사람입니다 2) 입니까, 의사입니다 3) 입니까, 목수입니다

## 활동 សកម្មភាព

〈보기〉처럼 친구들과 이름, 국적, 직업을 묻고 대답해 보세요.
សូមធ្វើតាម<ឧទាហរណ៍>ដោយសាកល្បងសួរនិងឆ្លើយតបទៅមិត្តភក្តិអំពីឈ្មោះ, សញ្ជាតិនិងមុខរបរ។

**보기**

투안: 이름이 무엇입니까? តើអ្នកឈ្មោះអ្វី?
리한: 리한입니다. ខ្ញុំគឺរីហាន់។
투안: 어느 나라 사람입니까? តើអ្នកគឺជាជនជាតិអ្វី?
리한: 파키스탄 사람입니다. ខ្ញុំគឺជាជនជាតិប៉ាគីស្ថាន។
투안: 회사원입니까? តើអ្នកគឺជាបុគ្គលិកក្រុមហ៊ុនរឺ?
리한: 네, 회사원입니다. បាទ, ខ្ញុំគឺជាបុគ្គលិកក្រុមហ៊ុន។

| | 이름 ឈ្មោះ | 국적 សញ្ជាតិ | 직업 មុខរបរ |
|---|---|---|---|
| 보기 | 리한 រីហាន់ | 파키스탄 사람 ជនជាតិប៉ាគីស្ថាន | 회사원 បុគ្គលិកក្រុមហ៊ុន |
| 1 | | | |
| 2 | | | |
| 3 | | | |
| 4 | | | |
| 5 | | | |

## 유용한 표현 កន្សោមពាក្យសំខាន់ៗ

**처음 뵙겠습니다.** ជាលើកទីមួយហើយដែលបានជួបអ្នក។

가: 만나서 반가워요. រីករាយណាស់ដែលបានជួបអ្នក។
나: 투안이라고 합니다. **처음 뵙겠습니다.** ខ្ញុំមានឈ្មោះថាធូអាន់។ ជាលើកទីមួយហើយដែលបានជួបអ្នក។

## 문화 អំពីវប្បធម៌

# 인사 예절 សុជីវធម៌ក្នុងការសម្ដែងការគួរសម

자신보다 나이가 많거나 지위가 높은 사람과 인사할 때

ការសម្ដែងការគួរសមទៅកាន់មនុស្សដែលមានឋានៈខ្ពស់ជាងរឺក៏មានអាយុច្រើនជាងខ្លួនយើង។



처음 만나는 사람과 인사할 때

ការសម្ដែងការគួរសមទៅកាន់មនុស្សដែលទើបតែជួបគ្នាជាលើកដំបូង។



직장 동료나 아는 사람과 인사할 때

ការសម្ដែងការគួរសមទៅកាន់មិត្តរួមការងាររឺក៏មនុស្សដែលស្គាល់គ្នា។



자신보다 나이가 어리거나 친한 사람과 인사할 때

ការសម្ដែងការគួរសមទៅកាន់អ្នកដែលមានអាយុក្មេងជាងរឺក៏មនុស្សដែលមានភាពជិតស្និទ្ធនឹងយើង។



## 내용 확인 ពិនិត្យខ្លឹមសារ

✚ 빈칸에 알맞은 말을 쓰세요. សូមបំពេញចន្លោះនូវពាក្យដែលត្រឹមត្រូវ។

(1) 어른을 만나면 '□□□□□'라고 인사합니다.
នៅពេលដែលជួបជាមួយមនុស្សដែលមានវ័យច្រើនជាងខ្លួន ពេលសម្ដែងការគួរសមត្រូវនិយាយថា៖ ជម្រាបសួរ។

(2) 처음 만나는 사람에게는 '□□□ □□□□□'라고 인사합니다.
នៅពេលជួបនរណាម្នាក់ជាលើកដំបូង ពេលសម្ដែងការគួរសមត្រូវនិយាយថា៖ រីករាយណាស់ដែលបានជួបអ្នក។

(3) 친구를 만나면 '□□'이라고 인사합니다.
ប្រសិនបើជួបមិត្តភក្តិ ពេលសម្ដែងការគួរសមត្រូវនិយាយថា៖ សួស្ដី។

정답 (1) 안녕하세요 (2) 만나서 반갑습니다 (3) 안녕

# EPS-TOPIK 듣기 វិញ្ញាសាស្តាប់ EPS-TOPIK



ចាប់ពីសំណួរទី១ដល់ទី៣ គឺជាការស្តាប់ពាក្យគន្លឹះ បន្ទាប់មកជ្រើសរើសយកសញ្ញាតិ។
សូមស្តាប់ដោយយកចិត្តទុកដាក់ បន្ទាប់មកជ្រើសរើសយកពាក្យដែលត្រឹមត្រូវ។

[1~3] 들은 것을 고르십시오. សូមជ្រើសរើសយកចម្លើយដែលអ្នកបានស្តាប់លឺ។

Track 24

1. ① 중국 ② 네팔 ③ 한국 ④ 몽골

2. ① 태국 ② 미얀마 ③ 베트남 ④ 필리핀

3. ① 동티모르 ② 스리랑카 ③ 캄보디아 ④ 파키스탄



សំណួរទី៤និងទី៥ សូមមើលរូបភាព បន្ទាប់មកជ្រើសរើសយកមុខរបរណាមួយដែលត្រឹមត្រូវ។
មុននឹងស្តាប់ការសន្ទនា សូមពិនិត្យមើលរូបភាពដែលបានបង្ហាញដូចខាងក្រោមនេះជាមុនសិន។

[4~5] 다음 그림을 보고 알맞은 것을 고르십시오.
សូមមើលរូបភាពខាងក្រោម បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវ។

4.  ① ② ③ ④

5.  ① ② ③ ④



## 듣기 대본 អត្ថបទនៅក្នុងវិញ្ញាសាស្ដាប់

1. 여: 한국 កូរ៉េ
2. 남: 미얀마 មីយ៉ាន់ម៉ា
3. 여: 동티모르 ទីម័រខាងកើត
4. ① 남: 의사 វេជ្ជបណ្ឌិត　② 남: 목수 ជាងឈើ
   ③ 남: 학생 សិស្ស　④ 남: 주부 មេផ្ទះ
5. ① 여: 회사원 បុគ្គលិកក្រុមហ៊ុន　② 여: 소방관 អ្នកពន្លត់អគ្គិភ័យ
   ③ 여: 요리사 ចុងភៅ　④ 여: 기술자 អ្នកបច្ចេកទេស

정답 1. ③ 2. ② 3. ① 4. ① 5. ③

## 확장 연습 លំហាត់អនុវត្តបន្ថែម

L-06

1. 들은 것을 고르십시오. សូមជ្រើសរើសយកចម្លើយដែលអ្នកបានស្ដាប់លឺ។

   ① 태국　② 라오스　③ 캄보디아　④ 방글라데시

2. 질문을 듣고 알맞은 대답을 고르십시오.
   សូមស្ដាប់សំណួរ បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវ។

   ① 네, 학생입니다.　② 네, 회사원입니다.
   ③ 아니요, 한국 사람입니다.　④ 아니요, 태국 사람입니다.

3. 다음 그림을 보고 알맞은 것을 고르십시오.
   សូមមើលរូបភាពខាងក្រោម បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវ។



   ①　②　③　④

## 확장 연습 듣기 대본 អត្ថបទស្ដាប់នៅក្នុងលំហាត់អនុវត្តបន្ថែម

1. 남: 캄보디아 កម្ពុជា
2. 남: 한국 사람입니까? តើអ្នកគឺជាជនជាតិកូរ៉េឬ?
3. 남: ① 기술자 អ្នកបច្ចេកទេស　② 요리사 ចុងភៅ
   ③ 경찰관 មន្ត្រីប៉ូលីស　④ 회사원 បុគ្គលិកក្រុមហ៊ុន

정답 1. ③ 2. ④ 3. ④

# EPS-TOPIK 읽기 វិញ្ញាសាអាន EPS-TOPIK

សំណួរទី១និងទី២ គឺជាពាក្យគន្លឹះដែលបង្ហាញអំពីមុខរបរចិញ្ចឹមជីវិត។ សូមមើលរូបភាព បន្ទាប់មកជ្រើសរើសយកចម្លើយដែលត្រឹមត្រូវ។

[1~2] 다음 그림을 보고 맞는 단어를 고르십시오.
សូមមើលរូបភាពខាងក្រោម បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវ។

1. 

① 회사원 ② 선생님
③ 경찰관 ④ 공무원

2. 

① 점원 ② 어부
③ 목수 ④ 농부

សំណួរទី៣ គឺជាការជ្រើសរើសយកពាក្យដែលទាក់ទងទៅនឹងសញ្ញាតិ។ សំណួរទី៤ គឺជាការសាកសួរឈ្មោះ។ ចំណែកឯសំណួរទី៥វិញ គឺជាសំណួរដែលចង់បញ្ជាក់ថា៖ 'មែន'រឺក៏'អត់មែន'។ សូមរំលឹកអំពីអ្វីដែលអ្នកបានរៀនរួចមកហើយនោះបណ្តើរ និងធ្វើការដោះស្រាយសំណួរបណ្តើរ។

[3~5] 빈칸에 들어갈 가장 알맞은 것을 고르십시오.
ចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវបំផុតដើម្បីបំពេញចន្លោះ។

3. 저는 베트남 __________입니다. ខ្ញុំគឺជាជនជាតិវៀតណាម។

① 몽골 ② 사람 ③ 인사 ④ 나라

4. 가: __________이 무엇입니까? តើអ្នកឈ្មោះអ្វី?
나: 리한입니다. ខ្ញុំឈ្មោះរីហាន់។

① 한국 ② 직업 ③ 이름 ④ 점원

5. 가: 학생입니까? តើអ្នកគឺជាសិស្សឬ?
나: __________, 회사원입니다. មិនមែនទេ, ខ្ញុំគឺជាបុគ្គលិកក្រុមហ៊ុន។

① 네 ② 아니요 ③ 괜찮아요 ④ 감사합니다

정답 1. ② 2. ④ 3. ② 4. ③ 5. ②



## 확장 연습 លំហាត់អនុវត្តបន្ថែម

[1~2] 다음 그림을 보고 맞는 문장을 고르십시오.
សូមមើលរូបភាពខាងក្រោម បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវ។

1.  

① 태국 사람입니다. ② 라오스 사람입니다.
③ 미얀마 사람입니다. ④ 캄보디아 사람입니다.

2. 

① 장화 ② 양말
③ 베개 ④ 구두

[3~4] 빈칸에 들어갈 가장 알맞은 것을 고르십시오.
ចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវបំផុតដើម្បីបំពេញចន្លោះ។

3.
가: ____________________?
나: 아니요, 농부입니다. មិនមែនទេ, ខ្ញុំគឺជាកសិករ។

① 농부입니까 ② 목수입니까
③ 투안 씨입니까 ④ 어느 나라 사람입니까

4.
가: 축하합니다. អបអរសាទរ។
나: ____________________?

① 감사합니다 ② 잘 먹겠습니다
③ 안녕히 주무세요 ④ 주말 잘 보내세요

정답 1. ④ 2. ② 3. ② 4. ①

## 발음 ការបញ្ចេញសម្លេង

P-01

### សូមស្តាប់ដោយយកចិត្តទុកដាក់ រួចថាតាម

នៅក្នុងភាសាកូរ៉េមានស្រៈទោលចំនួន៨( 아, 이, 우, 애, 오, 에, 어, 으 )។ ប៉ុន្តែ ក្នុងចំនោមស្រៈទោលទាំង៨នេះ មានស្រៈ 'ㅔ [e]' និង 'ㅐ [ɛ]'ដែលក្មេងៗសម័យក្រោយនេះ ពួកគេហាក់បីដូចជាមិនបានបែងចែកសម្លេងទាំង២នេះឲ្យបានច្បាស់លាស់នោះទេ។

(1) 이, 에, 애, 아
(2) 우, 오, 어, 아
(3) 우, 으
(4) 아이, 오이, 아우, 우애